# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/ ៥៩០

## ស្តីពី
## ការកែសម្រួលមាត្រាមួយចំនួន
## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥
## ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

---

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១៥ មាត្រា១៨ មាត្រា២០ មាត្រា២១ មាត្រា២៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៦ មាត្រា៤៩ និងមាត្រា៥០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានធ្វើការកែសម្រួល ដូចតទៅ÷

**មាត្រា៦.-ថ្មី**

គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវបង្កើតដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ តាមសំណើរួមរបស់ក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

ព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្ដីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល និងត្រូវកំណត់លម្អិតជាអាទិ៍នូវ បេសកកម្ម បុព្វសិទ្ធិ កាតព្វកិច្ច សមាសភាពនៃក្រុមប្រឹក្សាភិបាល ព្រមទាំងវិធានសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យលើគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យនេះ ត្រូវកំណត់ផងដែរនូវក្រសួង ស្ថាប័នដែលជាអាណាព្យាបាល។



**មាត្រា៧.-ថ្មី**

ការបញ្ចូលគ្នា ការបំបែកចេញ ការកែប្រែ និងការរំលាយគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ តាមសំណើរួមរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ទ្រព្យសកម្មជាចលនវត្ថុនិងអចលនវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ក្នុងករណីដូចគ្នា ចំពោះទ្រព្យសកម្មជារូបិយវត្ថុ ត្រូវបង្វែរចូលគណនីទោលរបស់រតនាគារជាតិ។

**មាត្រា៨.-ថ្មី**

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្មតម្រង់ទិសការអនុវត្តនិងត្រួតពិនិត្យសកម្មភាពការងាររបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងក្របខ័ណ្ឌនៃកម្មវត្ថុរបស់សាមីគ្រឹះស្ថានសាធារណៈរដ្ឋបាល ដូចមានកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។

**មាត្រា៩.-ថ្មី**

ក្រុមប្រឹក្សាភិបាល ត្រូវមានសមាសភាពយ៉ាងតិច ៥(ប្រាំ) រូប និងយ៉ាងច្រើន ៩(ប្រាំបួន) រូប។ ក្នុងករណីចាំបាច់ ចំនួនក្រុមប្រឹក្សាភិបាលអាចបន្ថែមដល់១១(ដប់មួយ)រូប។ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមានតំណាងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសតំណាងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និងអាចមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

នាយកនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាសមាជិកក្រុមប្រឹក្សាភិបាល។

**មាត្រា១០.-ថ្មី**

ប្រធាន និងសមាសភាពក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល, សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

**មាត្រា១១.-ថ្មី**

ក្រុមប្រឹក្សាភិបាល មានតំណាងបុគ្គលិករបស់គ្រឹះស្ថាន ១ (មួយ) រូប ជាសមាជិកស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយបុគ្គលិករបស់គ្រឹះស្ថាន សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ ដោយអនុលោមតាមនីតិវិធីដែលកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល។ តំណាងបុគ្គលិក ត្រូវក្លាយជាសមាជិកក្រុមប្រឹក្សាភិបាល តាំងពីថ្ងៃជាប់ឆ្នោតដោយមិនចាំបាច់មានការតែងតាំងឡើយ។ នៅពេលចប់អាណត្តិ ឬលាឈប់ពីការងារ តំណាងបុគ្គលិកនេះ ត្រូវបាត់បង់សមាជិកភាពក្រុមប្រឹក្សាភិបាលដោយស្វ័យប្រវត្តិ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា១៥.-ថ្មី**

ក្រុមប្រឹក្សាភិបាលមានភារកិច្ច ដូចតទៅ៖

- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទាំងសម្រាប់រយៈពេលមធ្យម ទាំងសម្រាប់រយៈពេលវែង
- ពិនិត្យនិងអនុម័តគម្រោងថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យនិងអនុម័តរបាយការណ៍គ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល របាយការណ៍ហិរញ្ញវត្ថុ របាយ-ការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ជំរុញដំណើរការរបស់គណៈកម្មាធិការ និងគណៈកម្មការ ដែលបង្កើតឡើងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងបង្កើតគណៈកម្មាធិការ និងគណៈកម្មការនានាតាមការចាំបាច់
- កំណត់នូវនីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិ ឬការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពិនិត្យនិងអនុម័តលើសំណើសុំកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត។

**មាត្រា១៨.-ថ្មី**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ។ លេខាធិការនេះ ពុំមានសិទ្ធិបោះឆ្នោតឡើយ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៤៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា២០.-ថ្មី**

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ដឹកនាំ និងគ្រប់គ្រងអង្គភាពប្រតិបត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវតែងតាំង និងបញ្ចប់ពីមុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ឬដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស។

មុខងាររបស់នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល។

មាត្រា២១.-ថ្មី

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល ជាតំណាងរបស់គ្រឹះស្ថាន ក្នុងការទំនាក់ទំនងជាមួយតតិយជន។

នាយកគ្រឹះស្ថានសាធារណៈរដ្ឋបាល បំពេញមុខងារក្នុងក្របខ័ណ្ឌនៃការប្រគល់សិទ្ធិអំណាច ដោយអនុលោមតាមព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល និងមានភារកិច្ច ដូចតទៅ÷

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនិងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍គ្រឹះស្ថានសាធារណៈរដ្ឋបាល ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ នូវភារកិច្ចរបស់អង្គភាពចំណុះនានានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនមន្ត្រីរាជការនិងបុគ្គលិករបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយផ្សេងទៀត ដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា២៦.-ថ្មី**

នាយកគ្រឹះស្ថាន ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលទទួលបានការប្រគល់សិទ្ធិពីក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ដែលជាអាណាប័កដើមខ្សែ ដោយមានសិទ្ធិអំណាចដូចតទៅ÷

- បញ្ជា និងជម្រះចំណូល
- បញ្ជាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ នាយកគ្រឹះស្ថានអាចផ្ទេរសិទ្ធិនេះបន្តឱ្យអាណាប័កជំនួសដោយមានការយល់ព្រមពីអាណាប័កដើមខ្សែ។

អាណាព្យាបាលបច្ចេកទេស ត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថាន តាមសំណើរបស់នាយកគ្រឹះស្ថាន និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម÷

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ៣(បី) ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣១.-ថ្មី**

គណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន÷

- គណនេយ្យទូទៅដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣២.-ថ្មី**

ថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាមូលនិធិសាធារណៈរបស់រដ្ឋ។

ថវិកាផ្ទាល់របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពឧបត្ថម្ភធនពីថវិការដ្ឋ ត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រើប្រាស់គណនីនៅធនាគារពាណិជ្ជណាមួយ ឬច្រើនសម្រាប់គ្រប់គ្រងថវិកាដែលបានមកពីចំណូលផ្ទាល់ និងពីប្រភពផ្សេងៗទៀត។

**មាត្រា៣៦.-ថ្មី**

គ្រឹះស្ថានសាធារណៈរដ្ឋបាល មានអាណាព្យាបាល ២ (ពីរ) ដូចខាងក្រោម÷

១-អាណាព្យាបាលបច្ចេកទេស គឺក្រសួង ស្ថាប័នជំនាញទទួលបន្ទុកលើសកម្មភាពនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមការកំណត់ដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្ដីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលនោះ។

២-អាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៩.-ថ្មី**

គ្រឹះស្ថាន ឬអង្គភាពរដ្ឋទាំងឡាយណា ដែលអនុវត្តគោលនយោបាយរបស់អាណាព្យាបាលបច្ចេកទេស និងទទួលបានចំណូលពីការផ្ដល់សេវាសាធារណៈជាប្រចាំ ត្រូវប្រែក្លាយខ្លួនជាគ្រឹះស្ថានសាធារណៈរដ្ឋបាលជាចាំបាច់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យផ្សេងៗ រួចធ្វើសំណើរួមជូនរាជរដ្ឋាភិបាលសម្រាប់ការប្រែក្លាយគ្រឹះស្ថាន ឬអង្គភាពរដ្ឋ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងឡាយណា ដែលមានចំណូលផ្ទាល់គ្រប់គ្រាន់ និងពុំត្រូវការឧបត្ថម្ភធនពីថវិការដ្ឋ ហើយដែលបាននិងកំពុងផ្ដល់សេវាសាធារណៈដែលមានចរិតលក្ខណៈជាការធ្វើអាជីវកម្មប្រកួតប្រជែងជាមួយសេវាប្រហាក់ប្រហែលក្នុងវិស័យឯកជន ត្រូវប្រែក្លាយខ្លួនជាសហគ្រាសសាធារណៈជាចាំបាច់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យផ្សេងៗ រួចធ្វើសំណើរួមជូនរាជរដ្ឋាភិបាលសម្រាប់ការប្រែក្លាយគ្រឹះស្ថានសាធារណៈរដ្ឋបាលជាសហគ្រាសសាធារណៈ។

**មាត្រា៥០.-ថ្មី**

គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងឡាយណា ដែលត្រូវបានបង្កើតឡើងមុនការចូលជាធរមាន នៃព្រះរាជក្រឹត្យនេះ ត្រូវធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាឱ្យស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ និងព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលយ៉ាងយូរបំផុតត្រឹមដំណាច់ឆ្នាំ២០១៩។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៧១ណ. ១៨០៥. ៥៩៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**អូន ព័ន្ធមុនីរ័ត្ន**

លេខៈ៦០៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**